សួស្តី នៅក្នុងរូបភាពនេះគឺនិយាយអំពីរដូវភ្លៀង ដែលនៅក្នុងប្រទេសកម្ពុជាយើងចែកចេញជាពីររដូវ
រដូវទីមួយគឺរដូវភ្លៀង ដែលរដូវភ្លៀងចាប់ផ្តើមពីខែប្រាំ រហូតដល់ខែដប់ និងទីពីរគឺរដូវក្តៅ
រដូវក្តៅគឺចាប់ផ្តើមពីខែដប់មួយ រហូតដល់ខែបួន។
អញ្ចឹងមានន័យថារដូវទាំងពីរបែងចែកជាប្រាំមួយខែ ប្រាំមួយខែរដូវក្តៅ ប្រាំមួយខែរដូវភ្លៀង។
អញ្ចឹងនៅកម្ពុជាមានរដូវពីរ រដូវក្តៅ និងរដូវភ្លៀង។ ជាក់ស្តែងនៅក្នុងរូប នៅក្នុងរូបភាពទីមួយ
នៅក្នុងរូបភាពទីមួយ យើងឃើញមានទីក្រុងមួយ ដែលទីក្រុងគឺជាកន្លែងបណ្តុំមនុស្សរស់នៅ
បណ្តុំមនុស្សរស់នៅ ឬក៏បណ្តុំមនុស្សធ្វើការ ឬក៏ធ្វើការរកស៊ី។ អញ្ចឹងយើងឃើញនៅទីក្រុងនោះ
យើងឃើញមានផ្ទះ មានអគារខ្ពស់ៗជាច្រើន និងមានសាលារៀន និងមានសាលារៀន
និងប្រសិនបើយើងក្រឡេកមើលទៅខាងលើវិញ យើងឃើញមានដុំពពកជាច្រើន និងក្រាស់
និងដុំពពកមានពណ៌ខ្មៅ ហាក់បង្ហាញថានៅក្នុងរូបភាពទីមួយនេះ នឹងមានភ្លៀងឆាប់ៗ។
អញ្ចឹងនៅពេលដែលមេឃរកភ្លៀង នៅពេលដែលមេឃរកភ្លៀង ជាទូទៅមេឃនឹងប្តូរពណ៌
មានន័យថាពពកនឹងប្តូរទៅជាពណ៌ខ្មៅ ពពកនឹងប្តូរទៅជាពណ៌ខ្មៅ និងអាកាសធាតុប្រែជាត្រជាក់
និងត្រជាក់។ អញ្ចឹងមានន័យថានៅពេលដែលខ្យល់បក់មកមានអារម្មណ៍ថាត្រជាក់
និងយើងក្រឡេកមើលទៅខាងលើឃើញដុំពពកមានពណ៌ខ្មៅ មានន័យថា មានន័យថា
នឹងមានភ្លៀងឆាប់ៗ។ ជាក់ស្តែងនៅក្នុងរូបភាពទីមួយ ដែលយើងឃើញនៅក្នុងទីក្រុងមួយដែល
ដែលមានសាលារៀន មានអគារខ្ពស់ៗជាច្រើន មានផ្ទះ និងមានកន្លែងផ្សេងៗទៀតជាច្រើន
និងហាក់បីដូចជាបង្ហាញថានឹងមានភ្លៀងឆាប់ៗ ដោយសារតែមានដុំពពកពណ៌ខ្មៅ និងក្រាស់។

បន្ទាប់មករូបភាពទីពីរ រូបភាពទីពីរ យើងឃើញក្រោយពីដុំពពកនោះ
យើងឃើញក្រោយពីដុំពពកនោះមានពណ៌ខ្មៅ និងដុំពពកនោះក្រាស់
មានពណ៌ខ្មៅជាមួយនឹងខ្យល់ត្រជាក់ផង មួយសន្ទុះក្រោយមកក៏មានភ្លៀងធ្លាក់ ក៏មានភ្លៀងធ្លាក់។
យើងឃើញនៅទីក្រុងនោះមានភ្លៀងធ្លាក់មកយ៉ាងខ្លាំង
ដោយនៅពេលភ្លៀងនោះយើងឃើញមានផ្លេក ផ្លេកបន្ទោរ ឬក៏ផ្គរលាន់ខ្លាំងៗ។
ជាទូទៅនៅកម្ពុជានៅពេលដែលមានភ្លៀង គឺនៅពេលដែលយើងមានភ្លៀង
យើងត្រូវប្រញាប់ប្រញាល់ចូលផ្ទះ និងជាពិសេសយើងអត់ជ្រកនៅក្រោមដើមឈើ
ឬក៏កន្លែងដែលគ្មានសុវត្ថិភាពទេ។ ដោយសារតែនៅកម្ពុជា ពេលខ្លះ នៅពេលដែលមានភ្លៀងខ្លាំង
នៅពេលដែលមានភ្លៀងខ្លាំងមានផ្លេកបន្ទោរ ដែលផ្លេកបន្ទោរ ដែលផ្លេកបន្ទោរមើលទៅដូចជា
ដូចជាភ្លើងមួយ ដូចជាភ្លើងមួយដែលមានពន្លឺនៅលើមេឃ
ដែលនៅពេលដែលផ្លេកបន្ទោរនោះខ្លាំងនឹងមានរន្ទះបាញ់។
អញ្ចឹងនៅពេលដែលយើងឈរនៅក្រោមដើមឈើ ឬក៏កន្លែងដែលមាន គ្មានសុវត្ថិភាព
អញ្ចឹងយើងអាចត្រូវរន្ទះបាញ់ នៅពេលដែលរន្ទះបាញ់ចំមនុស្សអាចធ្វើឲ្យមនុស្សស្លាប់បាន

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដោយសារតែ ដោយសារតែកម្លាំងភ្លើង ដោយសារតែកម្លាំងភ្លើងពីរន្ទះបាញ់នោះខ្លាំង
អញ្ចឹងអាចធ្វើឲ្យមនុស្សយើងស្លាប់បាន និងប្រសិនបើបាញ់ចំផ្ទះ ឬក៏មានរន្ទះបាញ់ បាញ់ចំផ្ទះ
ឬក៏បាញ់ចំដើមឈើអាចធ្វើឲ្យផ្ទះនោះឆេះ  ឬក៏អាចធ្វើឲ្យដើមឈើនោះឆេះ អាចធ្វើឲ្យដើមឈើឆេះ
ឬក៏ដួលរលំបាន។ ជាទូទៅនៅពេលដែលមានភ្លៀង គឺមានខ្យល់ខ្លាំង គឺមានខ្យល់ខ្លាំង
ដូច្នេះអាចធ្វើឲ្យដើមឈើមួយចំនួនដួលរលំនៅតាមផ្លូវ
និងពេលខ្លះអាចធ្វើឲ្យដើមឈើមួយចំនួនដួលរលំទៅលើឡាន
ឬក៏ដួលរលំទៅលើម៉ូតូដែលកំពុងតែធ្វើដំណើរនៅតាមផ្លូវ។
ដូច្នេះនៅពេលភ្លៀងគឺមានគ្រោះថ្នាក់ណាស់
ប្រសិនបើអាចចៀសវាងបាននៅពេលដែលមានភ្លៀងខ្លាំង
យើងគួរតែស្វែងរកកន្លែងដែលមានសុវត្ថិភាព ដូចជាយើងត្រូវជ្រកនៅក្នុងផ្ទះ
មិនត្រូវជ្រកនៅខាងក្រៅ នៅ នៅក្រៅ ជាពិសេសគឺនៅក្រោមដើមឈើ
ពីព្រោះនៅពេលដែលភ្លៀងខ្លាំង និងមានរន្ទះបាញ់ រន្ទះបាញ់
នៅពេលដែលបាញ់ចំមនុស្សអាចធ្វើឲ្យយើងស្លាប់បាន ឲ្យយើង អាចធ្វើឲ្យយើងស្លាប់បាន
និងបាញ់ចំ រន្ទះបាញ់ បាញ់ចំឡាន ឬក៏បាញ់ចំផ្ទះ ឬក៏ដើមឈើអាចធ្វើឲ្យឆេះ អាចធ្វើឲ្យឆេះ។
អញ្ចឹងរដូវ អញ្ចឹងពេលខ្លះ នៅពេលដែលមានភ្លៀងខ្លាំងគឺមានគ្រោះថ្នាក់ណាស់
អញ្ចឹងយើងត្រូវទៅរកកន្លែងសុវត្ថិភាពដើម្បីជ្រក។ អញ្ចឹងនៅក្នុងរូបភាពនេះ នៅក្នុងរូបភាពទីពីរនេះ
យើងឃើញទីក្រុងដែលយើងឃើញមានអគារខ្ពស់ៗ មានផ្ទះ មានសាលារៀន
និងកន្លែងផ្សេងៗទៀត កំពុងតែមានភ្លៀងធ្លាក់យ៉ាងខ្លាំងជាមួយនឹង ជាមួយនឹងផ្លេកបន្ទោរ
ជាមួយនឹងផ្លេកបន្ទោរ និងផ្គរលាន់ខ្លាំងៗផងដែរ។

រូបភាពទីបី នៅពេលដែលមានភ្លៀងធ្លាក់ខ្លាំង ដូច្នេះមនុស្សម្នាត្រូវរត់ទៅរកកន្លែងជ្រក
និងកន្លែងដែលមានសុវត្ថិភាព។ អញ្ចឹងរូបភាពទីបីយើងឃើញមានមនុស្សកំពុងតែព្យាយាមរត់
ព្យាយាមរត់ដើម្បីកុំឲ្យទទឹកខ្លួន ពីព្រោះដោយសារតែភ្លៀងនោះខ្លាំង ដោយសារតែភ្លៀងខ្លាំង និង
និងប្រសិនបើយើងត្រូវ និងប្រសិនបើយើងត្រូវទឹកភ្លៀងយូរអាចនឹងធ្វើឲ្យយើងឈឺផងដែរ
ដូច្នេះនៅពេលដែលមានភ្លៀងខ្លាំងមនុស្សត្រូវរត់ប្រញាប់ប្រញាល់ទៅរកកន្លែងជ្រក
និងកន្លែងដែលមានសុវត្ថិភាព ប៉ុន្តែនៅកំលុងពេលដែលយើងរត់ទៅរកកន្លែងនោះ
យើងត្រូវតែប្រុងប្រយ័ត្នផងដែរ
ដោយសារតែនៅពេលដែលមានភ្លៀងធ្លាក់អាចធ្វើងាយស្រួលនឹងរអិល ងាយស្រួលនឹងរអិល។
អញ្ចឹងសូម្បីតែឡានម៉ូតូនៅពេលដែលមានភ្លៀងធ្លាក់ក៏យើងត្រូវបើកបរឲ្យមានប្រុងប្រយ័ត្នដែរ
ពីព្រោះងាយស្រួលរអិល ពីព្រោះងាយស្រួលរអិល។ អញ្ចឹងយើងឃើញមនុស្សម្នាកំពុងតែ
កំពុងតែរត់ទៅរកកន្លែងជ្រក ដែលយើងឃើញមានភ្លៀងធ្លាក់យ៉ាងខ្លាំងនៅក្នុងទីក្រុងនោះ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

រូបភាពទីបួន រូបភាពទីបួន ជាទូទៅនៅពេលដែលមានភ្លៀងធ្លាក់
នៅពេលដែលមានភ្លៀងធ្លាក់តែងតែមានទឹកគ្រប់ទីកន្លែង ដោយសារតែ
ដោយសារតែមានភ្លៀងធ្លាក់ខ្លាំង ដូច្នេះតែងតែមានទឹកគ្រប់ទីកន្លែង
អញ្ចឹងមិនត្រឹមតែអ្នកដើរមានការពិបាកទេ សូម្បីតែការបើកបរក៏មានការលំបាកដែរ។
ដែលយើងឃើញនៅក្នុងរូបភាពទីបួននេះ យើងឃើញមានមនុស្សជាច្រើន មានស្រីមានប្រុស
និងមានសត្វឆ្កែមួយក្បាលកំពុងតែដើរនៅតាមផ្លូវនៅពេលដែលមានមេឃភ្លៀងនោះ
និងមានមនុស្សខ្លះគឺគាត់ប្រើឆត្រដើម្បីបាំង ដើម្បីបាំងកុំឲ្យភ្លៀងទទឹកខ្លួន។ ជាទូទៅនៅកម្ពុជា
ជាទូទៅយើងអត់សូវប្រើឆត្រទេ យើងប្រើអាវភ្លៀង ដោយសារតែភាគច្រើនគឺយើងជិះម៉ូតូ
ប្រសិនបើយើង ប្រសិនបើយើងប្រើឆត្រនៅពេលដែលយើងកំពុងតែជិះម៉ូតូអាចធ្វើឲ្យខ្យល់
អាចធ្វើឲ្យខ្យល់ អាចធ្វើឲ្យខ្យល់ប៉ើងឆត្រនោះឡើងទៅលើបាន
អាចធ្វើឲ្យខ្យល់ប៉ើងឆត្រនោះឡើងទៅលើ និងយើងមានការពិបាក ពិបាកជិះម៉ូតូ
និងអាចធ្វើឲ្យយើងដួលផងដែរ
ដូច្នេះជាទូទៅនៅកម្ពុជានៅពេលដែលយើងជិះម៉ូតូភាគច្រើនគឺយើងពាក់អាវភ្លៀង
និងអ្នកខ្លះគាត់ដើរ និងអ្នកខ្លះគាត់ដើរ គាត់អាចប្រើឆត្របានដើម្បីកុំឲ្យទទឹកខ្លួន។
អញ្ចឹងនៅក្នុងរូបភាពទីបួននោះ យើងឃើញមានអ្នកខ្លះគាត់បាំងឆត្រ ប៉ុន្តែអ្នកខ្លះទៀត
គាត់អត់មានឆត្រយកមកតាមខ្លួន ដូច្នេះគាត់មានតែខំព្យាយាមរត់គេចពីភ្លៀងទៅរកកន្លែងជ្រក
ប៉ុន្តែដោយសារតែភ្លៀងខ្លាំង និងមានទឹកផងដែរ ដូច្នេះធ្វើឲ្យការធ្វើដំណើររបស់ពួកគាត់ពិបាកបន្តិច
ដែលយើងឃើញទឹកសឹងតែលិចឆ្កែ ដែលយើងឃើញនៅក្នុងរូបភាពទីបួន
យើងឃើញឆ្កែព្យាយាមដើរដោយយើងក្បាល យើងឃើញក្បាលនិងកន្ទុយរបស់វា
និងយើងឃើញមនុស្សចំនួន នៅក្នុងរូបភាពនេះមានមនុស្សបួននាក់ ដែល
យើងក្រឡេកមើលទៅបុរសម្នាក់ដែលគាត់ឈរជាប់ទៅនឹងជញ្ជាំង គាត់ឈរនៅខាងមុខហាង
ដោយគាត់មាន ដោយសារតែគាត់អត់មានឆត្រ ដូច្នេះគាត់បានយកប្រហែលជា
ប្រហែលជារបស់អ្វីមួយដែលអាចបាំងភ្លៀងបាន គាត់យកដៃ គាត់កាន់ដៃ គាត់កាន់របស់នោះ
ក្នុងដៃទាំងពីររបស់គាត់ និងយកមកបាំងក្បាលរបស់គាត់កុំឲ្យភ្លៀងទទឹក។
អញ្ចឹងប្រហែលជាគាត់យកថង់ប្លាស្ទិក ឬក៏ថង់ប្លាស្ទិក ឬក៏ ឬក៏ឯកសាររបស់គាត់
អញ្ចឹងដើម្បីការពារភ្លៀង ដើម្បីកុំឲ្យទទឹក ដើម្បីកុំឲ្យទទឹកក្បាល ឬក៏គាត់យក
ឬក៏គាត់យកថង់ប្លាស្ទិកយកមកបាំងលើក្បាលគាត់ ដោយសារតែប្រហែលជាគាត់មិនបានយកឆត្រ
ឬក៏អាវភ្លៀងមកជាមួយ និងយើងឃើញមានស្ត្រីម្នាក់ទៀតដែលគាត់ពាក់អាវក្រហម
ពាក់អាវក្រហមនិងខោស គឺគាត់ ដៃទាំងពីររបស់គាត់ ដៃទាំងពីររបស់គាត់យួរនូវរបស់
នៅក្នុងដៃរបស់គាត់ទាំងពីរ ប្រហែលជាកន្ត្រក ឬក៏ជាកាបូបរបស់គាត់។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ជឹងដោយសារតែគាត់ខ្លាច ដោយសារតែប្រសិនបើគាត់យួរទម្លាក់
ទម្លាក់ដែចុះទៅខាងក្រោមរបស់ទាំងពីរនោះអាចទទឹកបាន ដោយសារតែមានទឹកជាច្រើននៅលើ
នៅតាមផ្លូវ អញ្ជឹងគាត់ព្យាយាមលើកកាបូបរបស់គាត់ ឬក៏ គាត់ព្យាយាមលើកកាបូបរបស់គាត់
ឬក៏ប្រហែលជាកន្ត្រកដាក់អីវ៉ាន់ អញ្ជឹងគាត់ព្យាយាមលើកឲ្យផុតពីទឹកកុំឲ្យទទឹក
និងស្ត្រីម្នាក់ទៀតដែលមាន និងស្ត្រីម្នាក់ទៀតដែល ដែល ពាក់អាវសដៃខ្លី និងខោសជើងខ្លី
គាត់មានកាន់ឆត្រ គាត់មានកាន់ឆត្រនៅក្នុងដៃរបស់គាត់ គាត់មានកាន់ឆត្រនៅក្នុងដៃរបស់គាត់
អញ្ជឹងគាត់កំពុងតែដើរកាត់ទឹក និងដើរកាត់ភ្លៀងផងដែរ
និងសត្វឆ្កែមួយក្បាលកំពុងតែព្យាយាមដើរទៅរកកន្លែងជ្រក និងកន្លែងដែលអត់មានទឹកលិច
និងស្ត្រីម្នាក់ទៀតយើងឃើញគាត់ពាក់អាវដៃស ដៃខ្លី និងស្លៀកសំពត់ គាត់កំពុងតែដើរ
គាត់កំពុងតែដើរកាត់ទឹកដើម្បីទៅរកកន្លែងជ្រក ឬក៏ដើម្បីត្រលប់ទៅផ្ទះរបស់គាត់វិញ។
អញ្ជឹងនៅក្នុងរូបភាពទី ៤ នោះ ភ្លៀង ភ្លៀងចាប់ផ្ដើមខ្លាំង អញ្ជឹងអ្នកដែលមាន
អ្នកដែលមានឆត្រគឺគាត់អត់ទទឹកទេ ប៉ុន្តែអ្នកដែលអត់មានឆត្រគាត់នឹងទទឹកភ្លៀង
ដោយសារតែមានទឹកច្រើននៅតាមផ្លូវ និងគាត់
និងគាត់មិនអាចស្វែងរកកន្លែងជ្រកភ្លៀងបានទាន់ពេល។

បន្ទាប់មកទៀតរូបភាពទី ៥ រូបភាពទី ៥ យើងឃើញមិនត្រឹមតែអ្នកធ្វើដំណើរមានការពិបាក
អ្នកធ្វើដំណើរដោយថ្មើរជើង ដែលយើងហៅថាធ្វើដំណើរដោយការដើរ
អញ្ជឹងមិនត្រឹមតែពួកគាត់មានការលំបាកទេសូម្បីតែឡាននៅក្នុងរូបភាពទី ៥។ រូបភាពទី ៥
យើងឃើញមានឡានមួយ អញ្ជឹងគឺយើងឃើញឡាននោះមានការ ឡាននោះក៏មាន ក៏កំពុងតែបើក
ក៏កំពុងតែបើកនៅ នៅកន្លែងដែលមានភ្លៀងខ្លាំងនោះ។ ដែលយើងឃើញឡាន យើងឃើញឡាន
យើងឃើញមានកង់ មានកង់ឡានចំនួនបួន ប៉ុន្តែនៅក្នុងរូបភាពនេះយើងឃើញតែចំហៀង
ដូច្នេះយើងឃើញកង់ពីរ ប៉ុន្តែនៅចំហៀងមួយទៀតមានកង់ពីរទៀត
និងឡាននេះជាឡានប្រភេទឡានតូច ដែលយើងឃើញមានកញ្ចក់
យើងឃើញមានកញ្ចក់ដាក់សងខាងឡានដើម្បីមើលផ្លូវ ដើម្បីងាយស្រួលមើលផ្លូវ
និងយើងឃើញមានទ្វារឡាននិងបង្អួចឡាន អញ្ជឹងមានន័យថានៅពេលដែលយើងចុះពីឡាន
យើងអាចបើកទ្វារឡាននោះចុះ និងនៅពេលដែលយើង និងនៅពេលដែលយើងចង់
មិនចង់ប្រើម៉ាស៊ីនត្រជាក់ឡាន យើងអាចបើកកញ្ចក់ឡាននោះបាន
និងយើងឃើញនៅខាងមុខឡានយើងឃើញមានភ្លើង យើងឃើញមានភ្លើងស៊ីញ៉ូ
និងនៅខាងក្រោយឡានក៏មានភ្លើងស៊ីញ៉ូដែរ ដែលភ្លើងស៊ីញ៉ូទាំងពីរនេះ
មានន័យថានៅពេលដែលគាត់ចង់បត់ឆ្វេង ឬក៏គាត់ចង់បត់ស្ដាំ គាត់ត្រូវបើកភ្លើងស៊ីញ៉ូជាសញ្ញា
ពីព្រោះប្រសិនបើបត់ដោយគ្មានការបើកភ្លើងទេ អ្នកដែលជិះពីក្រោយគាត់អាចមាន អាចមិនដឹង

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដូច្នេះអាចបុកពីក្រោយឡានរបស់គាត់។ អញ្ចឹងជាទូទៅនៅពេលដែលមានភ្លៀងខ្លាំងនៅកម្ពុជា ឡានមួយចំនួនយើងអាចបើកភ្លើងនៅពេលដែលមានខ្លាំង ដើម្បីងាយស្រួលដែលឲ្យអ្នកដែលធ្វើដំណើរគាត់បានដឹងថានៅខាងមុខមានឡាន ឬក៏ដើម្បីឲ្យគាត់ដឹងថា ដើម្បី ដើម្បីឲ្យគាត់មានការប្រុងប្រយ័ត្ន ពីព្រោះដោយសារតែមាន ពីព្រោះនៅពេលដែលមានភ្លៀងខ្លាំងយើងពិបាកមើល យើងពិបាកមើលផ្លូវ ដោយសារតែមានភ្លៀងខ្លាំង មាន មានខ្យល់ ដូច្នេះធ្វើឲ្យយើងពិបាកមើលផ្លូវ ដូច្នេះយើងអាចបើកភ្លើងអំពូលឡានបាន ដើម្បីជាសញ្ញា ដើម្បីជាសញ្ញាថានៅខាងមុខមានឡាន ឬក៏ដើម្បីជាសញ្ញាឲ្យមានការប្រុងប្រយ័ត្ន។ អញ្ចឹងយើងឃើញឡាន យើងឃើញឡាននេះជាប្រភេទឡានតូច មានកង់ឡានចំនួនបួន មានកញ្ចក់ប្រើសម្រាប់មើលខាងក្រោយនៅពេលដែលយើងចង់ នៅពេលដែលយើងចង់បត់ឆ្វេង ឬក៏បត់ស្តាំ នៅពេលដែលយើងចង់ឈប់ចតកន្លែងណាមួយគឺយើងងាយស្រួលមើលក្រោយ និងយើងឃើញមានចង្កៀងនៅខាងមុខប្រើសម្រាប់បំភ្លឺផ្លូវ និងភ្លើងស៊ីញ៉ូនៅខាងមុខ និងនៅខាងក្រោយប្រើសម្រាប់ស៊ីញ៉ូនៅពេលដែលយើងចង់ឈប់នៅកន្លែងណាមួយដើម្បីជាសញ្ញា និងយើងឃើញនៅខាងគូទ ជិតគូទឡាន នៅចំហៀងឡានមានកន្លែងសម្រាប់ចាក់សាំង មានកន្លែងសម្រាប់ចាក់សាំង។ អញ្ចឹងយើងឃើញឡាននៅក្នុងរូបភាពទី ៥ នោះ បើកហាក់បីដូចជាយឺត បើកយឺត ដោយសារតែមានភ្លៀងធ្លាក់ខ្លាំង ដូច្នេះគាត់ត្រូវបើកបរឲ្យ គាត់ត្រូវបើកបរដោយមានការប្រុងប្រយ័ត្ន ពីព្រោះទីមួយនៅពេលដែលមានភ្លៀងខ្លាំងអាច អាចធ្វើឲ្យយើងងាយស្រួលរអិល។ ផ្លូវគឺរអិល អញ្ចឹងពិបាក ទីពីរផ្លូវខ្លះនៅកម្ពុជា ដូចជាជាក់ស្តែងនៅកម្ពុជាផ្លូវខ្លះគឺមាន គឺ គឺមានក្រឡុក ក្រឡុកមានន័យថាជាផ្លូវខូច ផ្លូវខូចដែលមានប្រហោង ដែលមានប្រហោង ដែលមានប្រហោងដែលយើងហៅថាផ្លូវក្រឡុក អញ្ចឹងនៅពេលដែលមានភ្លៀង មានទឹកនៅពាសពេញផ្លូវ អញ្ចឹងយើងអត់អាចមើលឃើញផ្លូវដែលមានក្រឡុកទេ ដូច្នេះប្រសិនបើយើងធ្លាក់ក្រឡុកនោះ អាចមានគ្រោះថ្នាក់បាន អញ្ចឹងនៅពេលដែលបើកបរនៅពេលភ្លៀងត្រូវមានការប្រុងប្រយ័ត្ន។ ជាក់ស្តែងឡាននេះ ជាក់ស្តែងឡាននៅក្នុងរូបភាពទី ៥ នេះ គឺគាត់បើកដោយមានការប្រុងប្រយ័ត្ន ដោយសារតែមានភ្លៀងធ្លាក់ច្រើន ប៉ុន្តែហាក់បីដូចជាមានការពិបាកបើកបរបន្តិចសម្រាប់គាត់ ដោយសារតែមានភ្លៀងធ្លាក់ខ្លាំង។

រូបភាពទី ៦ យើងឃើញមានម៉ូតូ យើងឃើញមានម៉ូតូមួយ ដែលម៉ូតូនោះយើងឃើញមានកង់ពីរ កង់មួយនៅខាងមុខកង់មួយទៀតនៅខាងក្រោយ និងយើងឃើញនៅខាងមុខម៉ូតូនោះ យើងឃើញមានចង្កៀង ចង្កៀងម៉ូតូសម្រាប់បំភ្លឺផ្លូវ ឬក៏ភ្លើងបំភ្លឺផ្លូវ និងយើងឃើញម៉ូតូនោះមានកញ្ចក់ពីរ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ពីព្រោះកញ្ចក់ប្រើសម្រាប់មើលក្រោយនៅពេលដែលយើងចង់ឆ្លង
ឬក៏យើងចង់មើលក្រោយថាតើនៅខាងក្រោយយើងមានឡានឬទេ មានឡានឬក៏ម៉ូតូឬទេ។
អញ្ចឹងនៅពេលដែលយើងចង់បត់ឆ្វេងបត់ស្ដាំយើងអាចមើលកញ្ចក់នោះបាន
និងយើងឃើញនៅខាងក្រោយរបស់គាត់ដូចជាមានឃ្លុបមួយ
ដែលឃ្លុបនោះប្រហែលជាគាត់ប្រើសម្រាប់ដាក់អីវ៉ាន់ ប្រហែលជាគាត់ប្រើសម្រាប់ដាក់អីវ៉ាន់
មានន័យថាប្រសិនបើគាត់ទៅផ្សារ ឬក៏គាត់ទិញរបស់អ្វីមួយ គាត់អាចដាក់អីវ៉ាន់នៅក្នុងឃ្លុបនោះ
ដោយសារតែម៉ូតូរបស់គាត់នៅខាងមុខអត់មានកន្ត្រក ដូច្នេះគាត់អាចដាក់ឃ្លុបខាងក្រោយបាន
និងយើងឃើញមាន យើងឃើញបុរសម្នាក់គាត់កំពុងតែជិះម៉ូតូនោះ គាត់កំពុងតែជិះម៉ូតូកាត់ភ្លៀង
ដែលគាត់ស្លៀកខោពណ៌ស អាវដៃខ្លីពណ៌បៃតង គាត់ពាក់មួកពណ៌ទឹកក្រូច
គាត់ពាក់មួកពណ៌ទឹកក្រូច មួករបស់គាត់ប្រហែលជាមួកការពារ
ដោយសារតែនៅពេលដែលជិះម៉ូតូយើងត្រូវតែពាក់មួកការពារ
ដើម្បីការពារក្បាលរបស់យើងនៅពេលដែលយើងដួលដោយចៃដន្យ។
អញ្ចឹងជាទូទៅនៅពេលដែលជិះម៉ូតូ ម៉ូតូត្រូវមានកញ្ចក់សងខាងដែលអាចមើលផ្លូវ
ដែលអាចមើលផ្លូវបាន និងពាក់មួកសុវត្ថិភាព ពាក់មួកការពារសុវត្ថិភាពនៅលើក្បាលជានិច្ច
នៅពេលដែលជិះម៉ូតូនៅតាមផ្លូវ អញ្ចឹងយើងឃើញបុរសម្នាក់ ម្នាក់ដែលពាក់អាវដៃខ្លីពណ៌បៃតង
និងខោសនោះ គាត់មានពាក់មួកការពារ គាត់មាន គាត់មានពាក់មួកការពារ។
ដោយសារតែក្នុងរូបភាពទី ៦ យើងឃើញមានភ្លៀងធ្លាក់កាន់តែខ្លាំងឡើងៗ
ដូច្នេះធ្វើឲ្យគាត់មានការពិបាកបើកបរ ដោយសារតែផ្លូវមួយចំនួនគឺមានទឹកជាច្រើន
និងផ្លូវមួយចំនួនមានក្រឡុក មានក្រឡុក ឬក៏ផ្លូវមួយចំនួនរលាក់ផង
ដូច្នេះនៅពេលដែលមានទឹកច្រើនធ្វើឲ្យគាត់ពិបាកដឹងថាផ្លូវនេះមានបញ្ហាឬអត់
អញ្ចឹងគាត់ត្រូវបើកបរយឺតៗ និងដោយសារតែមាន និងដោយសារតែនៅពេលដែលមានភ្លៀងខ្លាំង
គឺគាត់ពិបាកមើលផ្លូវ។ ដូច្នេះបើទោះបីជាគាត់ជិះម៉ូតូគាត់អាចបើកភ្លើង
គាត់អាចបើកភ្លើងដើម្បីជាសញ្ញាថានៅខាងមុខគឺមានម៉ូតូ ឬក៏មានឡាន
ដើម្បីឲ្យអ្នកផ្សេងទៀតបានដឹង។ អញ្ចឹងនៅពេលដែលមានភ្លៀងខ្លាំង គាត់អាចបើកភ្លើង
គាត់អាចប្រើប្រាស់ភ្លើងម៉ូតូនោះបាន។ អញ្ចឹងយើងឃើញគាត់ជិះដោយមានការប្រុងប្រយ័ត្ន
ដោយសារតែមានភ្លៀងធ្លាក់ និងមានទឹក មានទឹកនៅតាមផ្លូវ យើងឃើញទឹកនោះ
យើងឃើញស្ទើរតែពាក់កណ្ដាលកង់ម៉ូតូរបស់គាត់ ស្ទើរតែពាក់កណ្ដាលកង់ម៉ូតូរបស់គាត់
អញ្ចឹងប្រសិនបើគាត់មិនឆាប់ប្រញាប់ជិះត្រលប់ទៅផ្ទះ ឬកន្លែងសម្រាប់ជ្រកភ្លៀងទេ
ម៉ូតូរបស់គាត់អាចលិចទឹកបាន ម៉ូតូរបស់គាត់អាចលិចទឹកបាន និងនៅពេលដែលម៉ូតូលិចទឹក
គឺម៉ូតូនោះនឹងរលត់ គឺអត់ទៅមុខបានទេ និងអត់ ម៉ូតូនោះគឺអត់ឆេះ និងអត់អាចទៅមុខបានទេ
អញ្ចឹងគាត់ត្រូវធ្វើដំណើរឲ្យ គាត់ត្រូវធ្វើដំណើរយ៉ាងប្រញាប់ដើម្បីត្រលប់ទៅផ្ទះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ឬក៏កន្លែងដែលអត់មានទឹក អញ្ជឹង ឬក៏កន្លែងដែលគាត់អាចជ្រកភ្លៀងបាន
ដើម្បីចៀសឲ្យផុតពីការលិចម៉ូតូ ឬក៏ដើម្បីចៀសឲ្យផុតកុំឲ្យម៉ូតូគាត់មានបញ្ហា។

រូបភាពទី ៧ ដោយសារតែមានភ្លៀង ដោយសារតែមានភ្លៀងធ្លាក់
ដោយសារតែមានភ្លៀងធ្លាក់មិនឈប់ឈរកាន់តែខ្លាំងឡើងៗ យើងឃើញទឹកចាប់ផ្តើម
យើងឃើញទឹកចាប់ផ្តើមពាសពេញផ្លូវនិងលិច អញ្ជឹង យើងឃើញផ្លូវមួយចំនួនលិច
អញ្ជឹងយើងឃើញផ្លូវមួយចំនួនលិច ដែលរូបភាពទី ៧ នេះ យើងឃើញមានស្ត្រីម្នាក់និងបុរសម្នាក់
ដែលស្ត្រីចំណាស់ម្នាក់គាត់ពាក់អាវសដៃវែង និងមានខ្សែរមួយជួរនៅខាងមុខអាវរបស់គាត់
គាត់ស្លៀកសំពត់ពណ៌ស នៅក្នុងដៃខាងឆ្វេងរបស់គាត់មានកាន់ឆត្រមួយពណ៌
ពណ៌រាងដូចជាពងមាន់ មានន័យថាពណ៌រាងលឿងបន្តិចសបន្តិច ដែលយើងហៅថាពណ៌ពងមាន់
អញ្ជឹងដោយសារតែមានភ្លៀងខ្លាំង និងដោយសារតែមានភ្លៀងខ្លាំង
អញ្ជឹងគាត់ត្រូវប្រើឆត្រដើម្បីទទូរកុំឲ្យទទឹកខ្លួនគាត់ និងផ្លូវមួយចំនួនគឺចាប់ផ្តើមលិច
អញ្ជឹងគាត់ចាប់ផ្តើមដើរកាត់ទឹកដើម្បីត្រលប់ទៅផ្ទះរបស់គាត់វិញ ឬក៏ដើម្បី
គាត់ត្រូវដើរកាត់ទឹកដើម្បីទៅផ្សារទិញម្ហូបសម្រាប់ សម្រាប់ធ្វើម្ហូបថ្ងៃនេះ។
អញ្ជឹងបើទោះបីជាមានភ្លៀងខ្លាំង និងផ្លូវមួយចំនួនមានទឹកលិចក៏ដោយ
ប៉ុន្តែនៅតែមានមនុស្សគាត់ដើរឆ្លងកាត់ ដោយសារតែគាត់ត្រូវត្រលប់ទៅផ្ទះរបស់គាត់វិញ
ឬគាត់ត្រូវចាំបាច់ធ្វើកិច្ចការរបស់គាត់ អញ្ជឹងគាត់អាចពាក់អាវភ្លៀង ឬក៏គាត់អាចពាក់អាវភ្លៀង
ឬក៏ទទូរឆត្រ ដែលយើងឃើញបុរសម្នាក់ទៀតគាត់ពាក់អាវសដៃខ្លី គាត់ពាក់អាវសដៃខ្លី
និងខោជើងវែងពណ៌ខ្មៅ ខោជើងវែងពណ៌ខ្មៅ ក្នុងដៃរបស់គាត់ក៏មានកាន់ឆត្រដែរ
ដែលឆត្រនោះមានពណ៌ទឹកក្រូច និងពណ៌ស។ អញ្ជឹងគាត់កាន់ឆត្រគាត់កំពុងតែទទូរឆត្រ។ អញ្ជឹង
គាត់ដើរបណ្តើរគាត់ងាកក្រោយបណ្តើរ និងងើយមើលទៅខាងលើបន្តិចដើម្បីចង់ដឹងថាមេឃ
ដើម្បីមើលទៅមេឃថាតើរាំងភ្លៀងហើយឬនៅ។ ដោយសារតែភ្លៀងខ្លាំង
ដោយសារតែមើលឃើញទឹកលិច ដោយសារតែមើលឃើញទឹកលិចនៅតាមផ្លូវ
ដូច្នេះធ្វើឲ្យការធ្វើដំណើរមួយចំនួនគឺពិបាក ប៉ុន្តែនៅពេលដែលមានភ្លៀងខ្លាំង
គឺយើងចៀសមិនផុតពីការលិចផ្លូវទេ និងពេលខ្លះរថយន្តដែលមានឡាន ឬក៏ម៉ូតូមួយចំនួន ម៉ូតូ
ឬក៏ឡានមួយចំនួន គឺ គឺអត់ឆេះ មានន័យថាមិនអាចដំណើរការទៅមុខទៀតបាន
ដោយសារតែទឹកចូលទៅ ចូលទៅក្នុង ចូលទៅខាងក្នុងឡាន ឬក៏ខាងក្នុងម៉ូតូ ខាងក្នុងម៉ាស៊ីនឡាន
ឬក៏ខាងក្នុងម៉ាស៊ីនម៉ូតូ អញ្ជឹងធ្វើឲ្យម៉ូតូនោះរលត់អត់ដំណើរការបានទេ
អញ្ជឹងជាទូទៅនៅពេលដែលមានភ្លៀងខ្លាំងទឹកនៅកន្លែងខ្លះគឺលិចត្រឹមជង្គង់
កន្លែងខ្លះគឺលិចលើជង្គង់ទៀត ដោយសារតែ ដោយសារតែមានភ្លៀងខ្លាំងពេក
ដោយសារតែមានភ្លៀងខ្លាំងពេក។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

រូបភាពទី ៨ រូបភាពទី ៨ នៅ រូបភាពទី ៨ យើងឃើញមានភក់ យើងឃើញមានភក់ ឬក៏មានទឹក។
អញ្ចឹងប្រសិនបើផ្លូវមានដី ផ្លូវដី អញ្ចឹងនៅពេលដែលមានភ្លៀងធ្លាក់ខ្លាំង យើងឃើញដី
យើងឃើញដីនោះ យើងឃើញកន្លែងនោះមានភក់ច្រើន
អញ្ចឹងនៅពេលដែលយើងដើរជាពិសេសនៅពេលដែលពាក់ស្បែកជើងផ្ទាត់ ពាក់ស្បែកជើងផ្ទាត់
នៅពេលដែលយើងដើរលឿនអាចស្បែកជើងនោះផ្ទាត់ភក់នោះធ្វើឲ្យប្រឡាក់ ធ្វើឲ្យប្រឡាក់ខោអាវ
ឬក៏ប្រឡាក់ខ្នង ប្រឡាក់ខោអាវ ឬក៏ប្រឡាក់ខ្នងរបស់យើងបាន ដោយសារតែស្បែកជើងផ្ទាត់
គឺវាផ្ទាត់ខ្លាំងនៅពេលដែលយើងដើរកាត់ភក់។ អញ្ចឹងនៅពេលដែល អញ្ចឹងយើងឃើញរូបភាពទី ៨
យើងឃើញមានកន្លែងខ្លះដក់ទឹក កន្លែងខ្លះគឺមានភក់ កន្លែងខ្លះគឺមានភក់។ ភក់មានន័យថាគឺជាដី
ដីជាមួយនឹងទឹកភ្លៀងដែលធ្លាក់មក ដូច្នេះ យើង ដូច្នេះធ្វើឲ្យដីនោះប្រែក្លាយទៅជាភក់
ដែលយើងហៅថាភក់។ អញ្ចឹងភក់នោះនៅពេលដែលយើងដើរអាចខ្ទាត
អាចខ្ទាតធ្វើប្រឡាក់ខោអាវបាន អញ្ចឹងជាពិសេសនៅពេលដែលខែភ្លៀង
ខែភ្លៀងគឺងាយស្រួលប្រឡាក់ ប្រឡាក់ខោអាវណាស់
ដោយសារតែនៅពេលដែលយើងចេញទៅខាងក្រៅ នៅពេលដែលយើងដើរ
អាចធ្វើឲ្យផ្ទាត់ប្រឡាក់ខោអាវ ឬក៏នៅពេលដែលមានម៉ូតូ ឬក៏ឡានបើកឆ្លងកាត់អាចធ្វើឲ្យសាចទឹក
អាចធ្វើឲ្យសាចទឹក ឬក៏សាចភក់ត្រូវខ្លួនរបស់យើង និងអាចធ្វើឲ្យយើងប្រឡាក់អាវ
ឬក៏ប្រឡាក់ខោបានយ៉ាងងាយស្រួល។

រូបភាពទី ៩ យើងឃើញមានក្មេងពីរនាក់។ រូបភាពទី ៩
ឃើញមានក្មេងប្រុសពីរនាក់កំពុងតែលេងទឹកភ្លៀងយ៉ាងសប្បាយរីករាយ។
ជាទូទៅក្មេងគឺចូលចិត្តមុជទឹកភ្លៀងនៅពេលដែលមានភ្លៀងធ្លាក់ និងចូលចិត្តលេង
ដោយសារតែនៅតាមផ្លូវមានទឹកច្រើន និងមានទឹកភ្លៀង និងមានភ្លៀងជាច្រើន
ដូច្នេះក្មេងៗចូលចិត្តមុជទឹកលេង។ អញ្ចឹងយើងឃើញក្មេងៗពីរនាក់នៅក្នុងរូបភាពនេះ
ក្មេងទីមួយមាន ក្មេងទីមួយស្លៀកខោសជើងខ្លី អត់ពាក់អាវទេ
និងក្មេងទីពីរស្លៀកខោពណ៌ទឹកក្រូចនិងពណ៌ស ក្មេងទីពីរក៏អត់មានពាក់អាវដែរ។
អញ្ចឹងក្មេងប្រុសទាំងពីរកំពុងតែរត់ កំពុងតែរត់លេង
ដោយក្មេងប្រុសដែលស្លៀកខោពណ៌ទឹកក្រូចជាមួយនឹងពណ៌ស
កំពុងតែរត់ដេញចាប់ក្មេងប្រុសដែលស្លៀកខោសជើងខ្លី ដែលអត់មានអាវនោះ។
អញ្ចឹងពួកគាត់ទាំងពីរកំពុងតែរត់ដេញគ្នាលេងកាត់ទឹកភ្លៀង អញ្ចឹងកំពុងតែរត់ រត់លេង
រត់ដេញគ្នាលេងកាត់ទឹកភ្លៀង ដែលកំពុងតែមានភ្លៀងធ្លាក់យ៉ាងខ្លាំង និងនៅតាមផ្លូវគឺមានទឹកដក់។
អញ្ចឹងពួកគេទាំងពីរលេងយ៉ាងសប្បាយរីករាយ ដែលក្មេងប្រុសដែលស្លៀកខោទឹកក្រូច

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ជាមួយនឹងពណ៌សកំពុងតែរត់ដេញចាប់ក្មេងប្រុសដែលស្លៀកខោពណ៌សជើងខ្លី
ដែលអត់មានពាក់អាវ។ អញ្ចឹងក្មេងប្រុសដែលស្លៀកខោជើងខ្លីគឺអត់មានពាក់អាវរត់បណ្ដើរ
ងាកក្រោយបណ្ដើរ ដើម្បីកុំឲ្យក្មេងប្រុសដែលស្លៀកខោពណ៌ទឹកក្រូច
និងពណ៌សនោះដេញតាមខ្លួនទាន់។

រូបភាពទី ១០ រូបភាពទី ១០ យើងឃើញមានអាងស្តុកទឹកមួយកន្លែង ដែលយើងឃើញ
ដោយសារតែមានសន្ទុះទឹកភ្លៀងខ្លាំងពេកធ្វើឲ្យអាងដែលស្តុកទឹកនោះមានទឹកជាច្រើនហូរ
មានទឹកជាច្រើនហូរ ហូរចូលទៅក្នុងអាងនោះ
ដូច្នេះនៅពេលដែលមានទឹកភ្លៀងហូរចូលទៅក្នុងអាងនោះច្រើន ដូច្នេះធ្វើឲ្យអាងនោះពេញ
នៅពេលដែលអាងនោះពេញ ទឹកមួយចំនួននឹងហូរចេញមកខាងក្រៅ។
អញ្ចឹងបើទោះបីជាមានរបងព័ទ្ធនៅទុក បើទោះបីជាមានរបងព័ទ្ធធ្វើជាទំនប់ទឹក
ដើម្បីកុំឲ្យទឹកដែលនៅក្នុងអាងនោះហូរចេញមកខាងក្រៅ ប៉ុន្តែដោយសារតែមានភ្លៀងខ្លាំងពេក
ដូច្នេះធ្វើឲ្យអាងស្តុកទឹកនោះ ធ្វើឲ្យអាងស្តុកទឹកនោះមិនអាចទប់ទឹកបាន ដូច្នេះទឹកមួយចំនួន
ទឹកខ្លះក៏បានហូរចេញមកខាងក្រៅ ក៏បានហូរចេញមកខាងក្រៅ។ អញ្ចឹងរូបភាពទី ១០
មានន័យថាចំនួន រូបភាពទី ១០ មានន័យថាទឹកដែលស្តុកនៅក្នុងអាង
ដោយសារតែមានភ្លៀងខ្លាំងពេក ទឹកនៅក្នុងអាងចាប់ផ្ដើមឡើង ចាប់ផ្ដើមឡើងខ្លាំង
និងធ្វើឲ្យហូរចេញទៅខាងក្រៅមួយចំនួន។

ចាស រូបភាពទី ១១ រូបភាពទី ១១ យើងឃើញមានផ្ទះ
យើងឃើញមានផ្ទះមួយដែលមានប្រក់ដំបូលក្បឿង មានប្រក់ដំបូលក្បឿង
និងមានបង្អួចដែលយើងឃើញមានបុរសម្នាក់គាត់កំពុងតែឈរសម្លឹងមកខាងក្រៅនៅតាមបង្អួច
គាត់ដាក់ដៃទាំងពីរនៅលើបង្អួចផ្ទះរបស់គាត់ និងគាត់កំពុងតែសម្លឹងមើលមកខាងក្រៅ
ដោយសារតែគាត់ឃើញមានមេឃភ្លៀងខ្លាំង និងនៅក្បែរផ្ទះគាត់មានពាងមួយ មានពាងទឹកមួយ
ពាងទឹកគឺប្រើសម្រាប់ផ្ទុកទឹកភ្លៀង ឬក៏ប្រើសម្រាប់ដាក់ទឹកប្រើប្រាស់
អញ្ចឹងនៅពេលដែលមានភ្លៀងធ្លាក់ខ្លាំង អញ្ចឹងផ្ទះរបស់គាត់ គាត់ធ្វើទ
ដែលទនោះមានន័យថាគាត់ធ្វើនៅតាមសំយាបផ្ទះរបស់គាត់ ដែល
ដែលដាក់ជិតនៅនឹងដំបូលរបស់គាត់ នៅពេលដែលមានភ្លៀងទឹកនឹងធ្លាក់ទៅលើដំបូល
បន្ទាប់មកនឹងធ្លាក់ចុះចូលទៅក្នុងទ ដូច្នេះទឹកនឹងហូរពីទចូលទៅក្នុងពាងនោះ
ដូច្នេះគាត់អាចប្រើប្រាស់នៅពេលដែល នៅពេលដែលគាត់ត្រូវការធ្វើម្ហូប
ឬក៏នៅពេលដែលគាត់ត្រូវការប្រើប្រាស់ធ្វើស្រែចំការអ្វីមួយគាត់អាចប្រើទឹកពាងនោះបាន។
អញ្ចឹងជាទូទៅទឹកភ្លៀងដែលយើងត្រងចេញពីទ ជាទូទៅគឺយើង គឺយើងទុកសម្រាប់ញ៉ាំ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គឺយើងទុកសម្រាប់ញ៉ាំ ឬក៏យើងទុកសម្រាប់ធ្វើម្ហូប ឬក៏ដាំបាយ ឬក៏ដាំទឹក
អញ្ចឹងយើងឃើញផ្ទះគាត់មានទ និងទឹកដែលហូរចេញពីលើដំបូលដែលប្រក់ក្បឿងនោះហូរចូលទ
និងទឹកនៅក្នុងទនោះហូរចូលពាង [ដែល]យើងឃើញពាងគាត់គឺធំ
អញ្ចឹងគាត់អាចប្រើទឹកនោះបានរយៈពេលយូរ។
អញ្ចឹងនៅពេលដែលមានភ្លៀងម្តងៗគាត់មានទឹកភ្លៀងសម្រាប់ប្រើប្រាស់
និងយើងឃើញមានដើមឈើផ្សេងៗទៀតនៅទីនោះផងដែរ និងយើងឃើញនៅខាង នៅខាង
យើងឃើញនៅលើដីមាន កន្លែងខ្លះមានទឹកដក់ ដោយសារតែមានភ្លៀងខ្លាំង
អញ្ចឹងកន្លែងខ្លះដែលទាបឬមានក្រឡុកមានទឹកដក់ អញ្ចឹងកន្លែងខ្លះដែលខ្ពស់
គឺអត់មានទឹកដក់ទេ។

រូបភាពទី ១២ រូបភាពទី ២ ទី ១២ យើងឃើញមានកសិករម្នាក់ ដែលកសិករនោះគាត់ពាក់អាវដៃវែង
ពណ៌សនិងពណ៌ទឹកក្រូច ជាមួយនឹងខោសជើងវែង គាត់មានពាក់មួកផងដែរ។
ដោយសារតែមានភ្លៀងដូច្នេះកសិករជាច្រើនគាត់ត្រូវការធ្វើស្រែរបស់គាត់
គាត់ត្រូវការធ្វើស្រែរបស់គាត់ ជាទូទៅស្រែនីមួយៗ គឺត្រូវការទឹក នៅពេលដែលមានទឹកធ្វើឲ្យ
ធ្វើឲ្យគាត់អាចធ្វើស្រែបាន និងស្រែរបស់គាត់ក៏ល្អផងដែរ។
អញ្ចឹងយើងឃើញបុរសម្នាក់នោះគាត់កំពុងតែ ប្រហែលជាគាត់កំពុងតែដាំស្រូវ
កំពុងតែដាំស្រូវដែលគាត់ ដែលគាត់កំពុងតែធ្វើស្រែរបស់គាត់ ធ្វើស្រែរបស់គាត់
ដែលយើងឃើញស្រែរបស់គាត់ពោរពេញទៅដោយទឹក ពោរពេញទៅដោយទឹក
អញ្ចឹងដោយសារតែមានភ្លៀងដូច្នេះគាត់ឆ្លៀតឱកាសធ្វើស្រែរបស់គាត់ឲ្យហើយ
ដោយសារតែស្រែនីមួយៗគឺត្រូវការទឹក គឺត្រូវការទឹក អញ្ចឹងគាត់ពាក់មួកដើម្បីការពារ
កុំឲ្យក្បាលរបស់គាត់ទទឹក ឬក៏ត្រូវភ្លៀង គាត់ពាក់អាវជើងវែង ឬក៏ខោជើងវែង គាត់កំពុងតែឱន
អញ្ចឹងបុរសម្នាក់នោះគាត់កំពុងតែឱនស្ទូងស្រូវ គាត់កំពុងតែឱនស្ទូងស្រូវ
ដោយសារតែស្រែរបស់គាត់គឺមានទឹកគ្រប់គ្រាន់សម្រាប់ស្ទូង[ស្រូវ] សម្រាប់ស្ទូងស្រូវ
ដូច្នេះធ្វើឲ្យគាត់សប្បាយចិត្តយ៉ាងខ្លាំង ដោយសារតែស្រែគឺត្រូវការទឹក
ដោយសារតែស្រែគឺត្រូវការទឹក ដូច្នេះនៅពេលដែលមានមេឃភ្លៀងធ្វើឲ្យកសិករគាត់មាន
គាត់មានអារម្មណ៍សប្បាយចិត្តយ៉ាងខ្លាំង។ ជាទូទៅការធ្វើស្រែគឺធ្វើនៅតាមទីជនបទ
គឺធ្វើនៅតាមទីជនបទ និងជា
និងកសិករមួយចំនួនគឺគាត់ពឹងទៅលើការធ្វើស្រែសម្រាប់ចិញ្ចឹមជីវិតរបស់ពួកគាត់
អញ្ចឹងប្រសិនបើមានភ្លៀងធ្វើឲ្យគាត់សប្បាយចិត្ត ពីព្រោះនឹងធ្វើឲ្យស្រូវនៅក្នុងស្រែរបស់គាត់
និងធ្វើឲ្យស្រូវនៅក្នុងស្រែរបស់គាត់លូតលាស់បានល្អ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដូច្នេះនៅពេលដែលស្រូវនៅក្នុងស្រែរបស់គាត់លូតលាស់បានល្អ គាត់ក៏អាចប្រមូលផលបានច្រើន និងអាចលក់នៅលើទីផ្សារបានលុយច្រើនផងដែរ។

រូបភាពទី ១៣ យើងឃើញមានមូស ជាទូទៅនៅពេលដែលមាន នៅពេលដែលមាន នៅពេលដែលរដូវភ្លៀង នៅពេលដែលរដូវភ្លៀង ឬមានភ្លៀងតែងតែមានមូសច្រើន ដែលយើងឃើញមូសនៅក្នុងរូបភាពទី ១៣ នេះ យើងឃើញជើងរបស់វាវែងៗ និងខ្លួនរបស់វាវែង និងក្បាលរបស់វាធំ និងវាមានស្លាប និងវាមានស្លាបនៅលើខ្នងរបស់វា និងមូសគឺមានពណ៌ខ្មៅនិងតូច មូសជាទូទៅគឺមានច្រើននៅ នៅខែភ្លៀង និងនៅពេលដែលមូស មូស ជាពិសេសគឺនៅពេលដែលយប់ ជាពិសេសគឺនៅពេលដែល គឺនៅពេលយប់ នៅពេលដែលមេឃងងឹតជាទូទៅមូសគឺចេញមកខាំដើម្បីបឺតឈាមមនុស្ស និងនៅពេលដែលមូសខាំយើងធ្វើឲ្យយើងមានការឈឺបន្តិច ឈឺបន្តិចនៅលើស្បែក និងពេលខ្លះក៏មានកន្ទួលនៅលើស្បែកផងដែរ ដោយសារតែវាខាំនិងបឺតឈាមរបស់យើង ប៉ុន្តែមូសខ្លះខាំនិងបឺតឈាមអាចចម្លងរោគមកយើងផងដែរ ដូចជាជំងឺគ្រុនឈាម ដូចជាជំងឺគ្រុនឈាមឆ្លងតាមមូសខ្លា និងជាពិសេសនៅពេលដែលខែភ្លៀងឪពុកម្តាយមួយចំនួន គឺគាត់ព្យាយាមឲ្យកូនៗរបស់គាត់ស្លៀកខោជើងវែង អាវដៃវែង ជាពិសេសកុំឲ្យពួកគាត់នៅកន្លែងដែលងងឹត ឬក៏កន្លែងដែលអត់មានពន្លឺ នៅកន្លែងងងឹត ឬក៏មិនឲ្យពួកគាត់ ឬក៏មិនឲ្យពួកគាត់ដោះអាវចេញទេ ដោយសារតែជាទូទៅមូសគឺវាខាំ និងបឺតជញ្ជក់ឈាមមនុស្ស និងជាពិសេសគឺក្មេងៗងាយស្រួលឆ្លងជំងឺគ្រុនឈាម ងាយស្រួលឆ្លងជំងឺគ្រុនឈាមនៅពេលដែលវាខាំនិងបឺតឈាមរបស់យើង និងមូសដោយសារតែខ្លួនរបស់វាតូចដូច្នេះពេលខ្លះគឺយើងពិបាក ពិបាកមើលឃើញ និងយើងដឹងថាមានមូសខាំដោយសារតែវាមកទំនៅលើ នៅលើស្បែករបស់យើង និងវាខាំ និងវាខាំបឺតជញ្ជក់ឈាមរបស់យើង ធ្វើឲ្យយើងមានការឈឺបន្តិចបន្តួច និងពេលខ្លះស្ទើរតែអត់ដឹង ស្ទើរតែអត់ដឹងថាឈឺ ប៉ុន្តែយើងនឹងឃើញមានស្នាមកន្ទួលនៅលើស្បែករបស់យើង នៅលើស្បែករបស់យើង និងមូសអាចឆ្លង មូសខ្លាចម្លងជំងឺគ្រុនឈាម និងពេលខ្លះជំងឺគ្រុនឈាម ប្រសិនបើយើងមិនអាចព្យាបាលទាន់ពេលទេអាចធ្វើឲ្យស្លាប់បាន ដោយសារតែជំងឺគ្រុនឈាម ជាជំងឺម្យ៉ាងក៏ស្ថិតនៅក្នុងជំងឺមួយដ៏ធ្ងន់ធ្ងរផងដែរ ប្រសិនបើយើងមិនបានព្យាបាលឲ្យទាន់ពេលវេលា។ អញ្ចឹងនៅខែភ្លៀងយើងត្រូវការពារកុំឲ្យមូសខ្លាខាំយើង ដើម្បីចៀសវាងជំងឺគ្រុនឈាម។

រូបភាពទី ១៤ រូបភាពទី ១៤ យើងឃើញមានព្រះអាទិត្យ យើងឃើញមានព្រះអាទិត្យ ដែលយើង ភាគច្រើន ដែលគាត់ច្រើននិយាយថាពេលមេឃភ្លៀង ក្រោយមេឃភ្លៀងមេឃស្រឡះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ក្រោយមេឃភ្លៀងមេឃស្រឡះ មានន័យថានៅពេលដែលមានភ្លៀងមានដុំពពកពណ៌ខ្មៅៗ
មានដុំពពកពណ៌ខ្មៅជាច្រើននិងក្រាស់ និងក្រោយពេលដែលមេឃភ្លៀងដុំពពកខ្មៅនោះបានរសាត់
បានរសាត់និងចាប់ផ្ដើម និងចាប់ផ្ដើមមានពន្លឺព្រះអាទិត្យ ដែលយើងហៅថា
ដែលយើងភាគច្រើននិយាយថាក្រោយមេឃភ្លៀង គឺក្រោយពេលភ្លៀងគឺមេឃស្រឡះ។
អញ្ចឹងជាក់ស្ដែងរូបភាពទី ១៤ ពពកដែលមានពណ៌ខ្មៅចាប់ផ្ដើមរសាត់ និងពពកពណ៌ស ចាប់
និងចាប់ផ្ដើមមានពពកពណ៌ស និងដោយសារតែដុំពពកនោះរសាត់ដូច្នេះធ្វើឲ្យមាន
ដូច្នេះធ្វើឲ្យយើងឃើញមាន យើងឃើញព្រះអាទិត្យរះចិញ្ចែងចិញ្ចាំងមក
មកលើផែនដីក្រោយពេលភ្លៀង។ អញ្ចឹងយើងឃើញក្រោយពេលមេឃភ្លៀង
ក្រោយពេលមេឃភ្លៀងយើងឃើញមានព្រះអាទិត្យរះ អញ្ចឹងគឺមានន័យថាគឺរាំងភ្លៀងហើយ
ឬក៏ឈប់ភ្លៀងទៀតហើយ។

បន្ទាប់មកទៀតរូបភាពចុងក្រោយ រូបភាពទី ១៥ រូបភាពទី ១៥ យើងឃើញមានភ្នំ
មានដើមឈើពណ៌បៃតង មានដើមឈើជាច្រើន មានដើមឈើជាច្រើនខុសៗគ្នា
ដែលមានពណ៌បៃតង ដែលមានពណ៌បៃតងអមជាមួយនឹងដុំពពកពណ៌ស
និងដុំពពកពណ៌ខ្មៅចាប់ផ្ដើមរសាត់និងមានពន្លឺព្រះអាទិត្យផងដែរ។
ជាទូទៅនៅក្រោយពេលដែលមានមេឃភ្លៀងធម្មជាតិចាប់ផ្ដើមលូតលាស់
និងយើងមើលទៅគឺមានពណ៌បៃតងស្រស់ ស្រស់ស្អាត។ ដោយសារតែដើមឈើ ឬក៏
ដោយសារតែដើមឈើនៅពេលដែល នៅពេលដែលត្រូវទឹកភ្លៀង វាចាប់ផ្ដើមលូតលាស់
និងស្លឹករបស់វាមើលទៅពណ៌បៃតង និងល្អ។ អញ្ចឹងដើមឈើវាត្រូវការទឹក
ដូចជាមនុស្សក៏ត្រូវការទឹកផងដែរ មនុស្សត្រូវការ ត្រូវការទឹក និងត្រូវការអាហារ
អញ្ចឹងដើមឈើអាហាររបស់វាគឺទឹក អញ្ចឹងវាត្រូវការទឹក ប្រសិនបើអត់មានទឹកទេក៏វាមិនអាចរស់នៅ
ដើមឈើនោះនឹងងាប់ វាអត់អាចរស់នៅបានទេ។ អញ្ចឹងអាហាររបស់ដើមឈើវាត្រូវការចាំបាច់ទឹក
អញ្ចឹងនៅពេលដែលមានភ្លៀងយើងឃើញនៅក្នុងរូបភាពទី ១៥
ធម្មជាតិទាំងអស់គឺចាប់ផ្ដើមប្ដូរទៅជាពណ៌បៃតង និងមើលទៅស្រស់ស្អាតអមជាមួយនឹងភ្នំ
អមជាមួយនឹងភ្នំ និងដុំពពកពណ៌ស
និងជាមួយនឹងព្រះអាទិត្យដែលកំពុងរះចែងចាំងពន្លឺយ៉ាងស្រស់ស្អាតជាមួយនឹងធម្មជាតិពណ៌បៃតង
នៅក្នុងរូបភាពទី ១៥ នេះ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.